Sipar



ខ្ញុំចង់ដឹង

ចាប់ពី 12 ឆ្នាំ

## ស្វែងយល់ពី

# ជំងឺឆ្កែឆ្កួត



ខ្ញុំចង់ដឹង



# ស្វែងយល់ពី ជំងឺឆ្កែឆ្កួត

និពន្ធដោយ
**លី សុវត្ថិ**
**ឌីឌីយេ ហ្វុងតឺនីយ (Didier FONTENILLE)**

*អ្នកទទួលខុសត្រូវបោះពុម្ពផ្សាយ ៖ ហុក សុទ្ធិ*
*អ្នកគ្រប់គ្រងកម្មវិធីបោះពុម្ព ៖ ហួត សុជាតា*
*អ្នកបោះពុម្ពផ្សាយ និងរចនាទំព័រ ៖ ហួត សារិទ្ធ*
*អ្នកពិនិត្យអត្ថបទ ៖ ក្រុមបោះពុម្ពផ្សាយ* Sipar



# មាតិកា


មនុស្សឈឺជំងឺឆ្កែឆ្កួតគឺស្លាប់១០០%.....4

ជំងឺឆ្កែឆ្កួតនៅប្រទេសកម្ពុជា ............... 8

ស្ថានភាពទូទៅនៃជំងឺឆ្កែឆ្កួត ............... 12

ហានិភ័យនៃជំងឺឆ្កែឆ្កួតនៅកម្ពុជា....... 16

វត្តមាននៃជំងឺឆ្កែឆ្កួតនៅកម្ពុជា........... 17

ជំងឺឆ្កែឆ្កួតអាចបង្ការបាន១០០%
ដោយចាក់ថ្នាំបង្ការ................................ 20

ធ្វើយ៉ាងណាជៀសវាងសត្វឆ្កែខាំ..........26

ការចាក់ថ្នាំបង្ការឱ្យសត្វឆ្កែ.................. 30

យល់ដឹងបន្ថែមពីអតីត និងអនាគត ...32

សាកល្បងរកចម្លើយ ............................ 42

ពន្យល់ពាក្យ........................................ 44

## ជំងឺឆ្កែឆ្កួតជាអ្វី?

ប្រជាជនកម្ពុជាគ្រប់រូបដឹងពីវត្តមានជំងឺឆ្កែឆ្កួត និងខ្លាចជំងឺនេះណាស់។ ជំងឺនេះឆ្លងពីសត្វដែលមានផ្ទុកមេរោគជំងឺឆ្កែឆ្កួតខាំ ឬខ្វាច។ បើសត្វនោះបង្ករបួសលើមនុស្ស វាអាចចម្លងមេរោគជំងឺឆ្កែឆ្កួតទៅមនុស្សបាន។ មនុស្សក៏នឹងធ្លាក់ខ្លួនឈឺ ហើយស្លាប់ បើគាត់មិនបានទទួលការចាក់ថ្នាំបង្ការត្រឹមត្រូវ និងទាន់ពេលវេលា។

ជំងឺនេះកើតមានច្រើនករណីនៅក្នុងប្រទេសកម្ពុជា ប៉ុន្តែគេអាចជៀសវាងជំងឺនេះបាន ដោយវិធានការសាមញ្ញដែលពិពណ៌នាក្នុងសៀវភៅនេះ។

ជំងឺឆ្កែឆ្កួតបណ្តាលឱ្យបាត់បង់ជីវិតក្នុង១០០%នៃករណីជំងឺដែលមានចេញជារោគសញ្ញា។ ប៉ុន្តែ ជំងឺនេះក៏អាចបង្ការបាន១០០%ដែរ ដោយការចាក់ថ្នាំបង្ការ រួមជាមួយវិធានការបង្ការផ្សេងៗបន្ថែមទៀត។

សូមប្អូនៗរៀនស្គាល់ជំងឺឆ្កែឆ្កួត រៀនការពារខ្លួនឯង និងពន្យល់ទៅមិត្តភក្តិក៏ដូចជាទៅមាតាបិតារបស់ប្អូនអំពីអ្វីដែលគួរធ្វើចំពោះមុខជំងឺនេះ។

សូមប្អូនៗរួមចំណែកជាតួអង្គមួយក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺឆ្កែឆ្កួត!



AIDOC
Date:
Donated by:




មនុស្សឈឺជំងឺឆ្កែឆ្កួតគឺស្លាប់១០០%
ខេត្តព្រៃវែង - នៅក្នុងគ្រួសារមួយដែល មានឪពុកជាកម្មករដាំបង្គោល និងរាយខ្សែភ្លើងនៅ តាមភូមិ...
ថ្ងៃមួយ
ជួយផង!
បងទៅម្ខាង សិនទៅ។
ជួយចាប់វា បងប្អូន!


ដោយឃើញឆ្កែនោះមានអាការៈខុសពីធម្មតា ម្ចាស់ឆ្កែក៏សម្លាប់ឆ្កែនោះទៅ។
ឱ្យឈឺង សុំទោសអាខ្លូ!
ចំណែកអ្នករបួសក៏ទៅកន្លែងពិគ្រោះជំងឺតូចមួយដែលនៅជិតនោះ។
មិនអីទេ លាងរបួសរួចហើយ។
គាត់ទទួលបានថ្នាំចាក់មួយម្ជុលដែលមិនមែនជាថ្នាំបង្ការជំងឺឆ្កែឆ្កួតទេ...
...និងថ្នាំសម្រាប់លេបចំនួន ៣ថ្ងៃ។
២០ថ្ងៃក្រោយមក គាត់មិនស្រួលខ្លួន និងមានអាការៈមិនប្រក្រតី ជួនឡេះឡះ ជួនអង្គុយសំកុកនៅកន្លែងងងឹតស្ងប់ស្ងាត់ ពិសាទឹកឬអាហារមិនកើត។
...គ្រុនក្ដៅ


...ពិបាកដកដង្ហើម
...ខាកស្ពោះញឹកញាប់
...ហៀរទឹកមាត់
ឃើញអាការៈដូចនេះ ប្រពន្ធគាត់ក៏ប្រញាប់នាំគាត់ទៅមន្ទីរពេទ្យស្រុក។
លឿនឡើងកូន ពុកឯងមិនស្រួលខ្លួនខ្លាំងហើយ!
នៅពេទ្យ
ត្រូវបញ្ជូនគាត់ទៅព្យាបាលនៅភ្នំពេញទើបបាន!
គាត់ក៏ត្រូវបានបញ្ជូនទៅមន្ទីរពេទ្យនៅភ្នំពេញភ្លាមៗ។


នៅភ្នំពេញ
បន្ទប់សង្គ្រោះបន្ទាន់
ថ្មីៗនេះ គាត់រងរបួសដោយឆ្កែខាំ។ ពេលនេះ រោគសញ្ញាជំងឺបញ្ជាក់ថា គាត់ឈឺជំងឺឆ្កែឆ្កួតហើយ។ ជំងឺនេះកាចសាហាវណាស់ មិនមានវិធីព្យាបាលទេ។ សូមបងស្រីកាត់ចិត្តទៅ។
ពីរថ្ងៃក្រោយ បន្ទាប់ពីចេញរោគសញ្ញាជំងឺ គាត់ក៏បានទទួលមរណភាព ក្រោមការសន្និដ្ឋានរបស់គ្រូពេទ្យថា ជាជំងឺឆ្កែឆ្កួត។

# ជំងឺឆ្កែឆ្កួតនៅប្រទេសកម្ពុជា

**នៅប្រទេសកម្ពុជា ជាទូទៅ ជំងឺឆ្កែឆ្កួតជាជំងឺកើតលើសត្វឆ្កែ និងឆ្លងទៅមនុស្សដោយសត្វឆ្កែខាំ។**

ហេតុអ្វីបានជាយើងចាប់អារម្មណ៍ទៅលើសត្វឆ្កែជាងគេ?
ព្រោះថា សត្វឆ្កែជាសត្វគូកនដែលប្រជាជនកម្ពុជាចូលចិត្តចិញ្ចឹម។ សត្វឆ្កែមានចំនួនច្រើននៅទូទាំងប្រទេសកម្ពុជា។ នៅតាមភូមិនានា ផ្ទះភាគច្រើនចិញ្ចឹមសត្វឆ្កែមួយ ឬច្រើនក្បាល។ វាមានប្រយោជន៍ ដោយវាចេះចាំការពារផ្ទះ។
ប៉ុន្តែ សត្វឆ្កែអាចឈឺជំងឺឆ្កែឆ្កួត អាចខាំមនុស្ស និងចម្លងជំងឺនោះទៅមនុស្សបាន។

## ជំរឿនសត្វឆ្កែ

តាមការអង្កេតរាប់ចំនួនសត្វឆ្កែតាមសហគមន៍ បានបង្ហាញថា តំបន់មួយចំនួននៃប្រទេសកម្ពុជា មានចំនួនសត្វឆ្កែធៀបនឹងចំនួនមនុស្សគឺប្រមាណឆ្កែ១ក្បាលសម្រាប់មនុស្ស៣ទៅ៥នាក់។ តាមរយៈព័ត៌មាននេះ យើងអាចគណនាបានថា ចំនួនសត្វឆ្កែមានពី៣ទៅ៥លានក្បាលក្នុងប្រទេសកម្ពុជា។

ឆ្កែរស់នៅតាមភូមិ



## ជំងឺឆ្កែឆ្កួតលើសត្វឆ្កែ

សត្វឆ្កែស្ទើរតែទាំងអស់នៅទូទាំងប្រទេសមិនបានទទួលការចាក់ថ្នាំបង្ការជំងឺឆ្កែឆ្កួតទេ។ ជារៀងរាល់ឆ្នាំ មានសត្វឆ្កែច្រើនរយក្បាលឈឺជំងឺឆ្កែឆ្កួត និងអាចចម្លងជំងឺនេះទៅសត្វផ្សេងៗ ឬទៅមនុស្ស។

រាល់ការផ្លាស់ប្តូរអត្តចរិតរបស់ឆ្កែ យើងត្រូវគិតដល់ជំងឺឆ្កែឆ្កួត។ សត្វឆ្កែដែលឈឺជំងឺឆ្កែឆ្កួត នឹងងាប់ក្នុងរវាងរយៈពេល៥ថ្ងៃ។ មិនត្រូវទៅក្បែរ ឬប៉ះពាល់សត្វឆ្កែឆ្កួតទាំងនោះទេ។

សត្វឆ្កែដែលឈឺជំងឺឆ្កែឆ្កួត អាចបង្ហាញរោគសញ្ញាជាពីរទម្រង់ ៖

**ទម្រង់កាច ៖** ជាទម្រង់ដែលគេស្គាល់ច្រើនជាងគេ និងលេចធ្លោជាងគេ។ ឆ្កែដែលឈឺ មានលក្ខណៈកាចខ្លាំង។ ចរិតធម្មជាតិរបស់វាផ្លាស់ប្តូរ ហើយវាអាចស្ទុះទៅខាំដោយគ្មានការបង្កហេតុ និងអាចខាំវត្ថុនានាដែរ។



ឆ្កែមានជំងឺឆ្កែឆ្កួតទម្រង់កាច

**ទម្រង់ស្រងូល ៖** សត្វឆ្កែបង្ហាញលក្ខណៈកាចតិចតួច និងមានហៀរទឹកមាត់ច្រើន។ ពេលវាព្រុស សំឡេងវាដូរប្លែកខុសធម្មតា។ វាមិនអាចលេបអាហារ ឬទឹកបានទេ។



ឆ្កែមានជំងឺឆ្កែឆ្កួតទម្រង់ស្រងូល

### ឱកាសឆ្លងជំងឺលើសត្វឆ្កែ

នៅប្រទេសកម្ពុជា សត្វឆ្កែភាគច្រើនមានម្ចាស់ចិញ្ចឹម។ មានឆ្កែតិចតួចដែលគ្មានម្ចាស់ រស់នៅតាមផ្សារ និងវត្តអារាមនានា។ ប្រជាជនកម្ពុជានៅក្រៅទីប្រជុំជនមិនមានទម្លាប់ចិញ្ចឹមឆ្កែដោយបង្ខាំងឱ្យនៅតែក្នុងបរិវេណផ្ទះនោះទេ។ គេច្រើនបណ្តោយឱ្យសត្វឆ្កែដើរទៅក្រៅដោយសេរី ព្រោះសត្វឆ្កែជាសត្វស្គាល់ម្ចាស់ និងស្គាល់ផ្ទះ។ វាកម្រទៅណាឆ្ងាយបាត់មិនត្រលប់មកវិញណាស់។

ការដែលអាចចេញទៅខាងក្រៅបានបែបនេះ សត្វឆ្កែមានឱកាសជួប និងខាំគ្នាជាមួយឆ្កែដទៃ។ បើវាខាំជាមួយឆ្កែណាដែលមានជំងឺឆ្កែឆ្កួត វាច្បាស់ជាឆ្លងជំងឺនេះមិនខាន។



ស្វា

## មិនមែនមានតែសត្វឆ្កែនោះទេដែលអាចមានជំងឺឆ្កែឆ្កួត

ថនិកសត្វទាំងអស់អាចឈឺជំងឺឆ្កែឆ្កួត។ នៅប្រទេសកម្ពុជា ក្រៅពីសត្វឆ្កែ សត្វដទៃទៀតក៏អាចឆ្លងជំងឺឆ្កែឆ្កួតដែរ។ ជាញឹកញាប់សត្វទាំងនោះមានដូចជាឆ្មា ស្វា ជ្រូក និងគោក៏អាចឈឺ បើត្រូវសត្វឆ្កែឆ្កួតខាំ។ ឯនៅប្រទេសមួយចំនួនទៀត សត្វព្រៃក៏អាចឈឺជំងឺនេះដែរ និងអាចចម្លងទៅមនុស្ស បើសត្វទាំងនោះខាំ។ ឧទាហរណ៍ ដូចជាប្រចៀវនៅអាមេរិកខាងត្បូង សំពោចមូហ្វែត (moufettes)នៅអាមេរិកខាងជើង ឆ្កែព្រៃអាហ្វ្រិកជាដើម។



ឆ្មា



គោ



ជ្រូក



សំពោចមូហ្វែត



ប្រចៀវ



ឆ្កែព្រៃអាហ្វ្រិក

## មេរោគជំងឺឆ្កែឆ្កួត

ជំងឺឆ្កែឆ្កួតជាជំងឺដែលប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ បង្កដោយមេរោគមួយតូចបំផុត ជាប្រភេទវីរុស។ យើងមិនអាចមើលឃើញនឹងភ្នែកទទេឡើយ ព្រោះវាតូចជាងសរសៃសក់ដល់ទៅ១ ០០០ដងឯណោះ គឺមានប្រវែងប្រមាណ៣០០ណាណូម៉ែត្រ។ បើយើងមើលវីរុសនេះដោយប្រើមីក្រូទស្សន៍អេឡិចត្រូនិក យើងនឹងឃើញវាមានទម្រង់ដូចក្បាលគ្រាប់កាំភ្លើងអឺចឹង។ គេចាត់វីរុសទាំងនោះក្នុងគ្រួសារវីរុសរ៉ាប់ដូវីរីដេ (Rhabdoviridae)។

### តើប្អូនដឹងទេ?

មីក្រូទស្សន៍អេឡិចត្រូនិកមានសមត្ថភាពឱ្យយើងមើលឃើញវីរុសតូចៗបំផុតគឺតូចជាងសរសៃសក់របស់ប្អូនរាប់ពាន់ដងឯណោះ។




មីក្រូទស្សន៍អេឡិចត្រូនិក



រូបវីរុសជំងឺឆ្កែឆ្កួតថតតាមរយៈមីក្រូទស្សន៍អេឡិចត្រូនិក

### តើប្អូនដឹងទេ?

*ជំងឺឆ្កែឆ្កួតមានវត្តមាននៅគ្រប់ទ្វីបទាំងអស់ លើកលែងតែនៅទ្វីបអង់តាកទិក។ ៩០%នៃជំងឺឆ្កែឆ្កួតលើមនុស្សបង្កដោយសត្វឆ្កែខាំ ហើយជនរងគ្រោះ៩៥%ស្ថិតនៅទ្វីបអាស៊ី និងទ្វីបអាហ្វ្រិក។ ជនរងគ្រោះ៤០%ជាកុមារអាយុក្រោម១៥ឆ្នាំ។*

# ស្ថានភាពទូទៅនៃជំងឺឆ្កែឆ្កួត

***ជំងឺឆ្កែឆ្កួតមានតាំងពីយូរយារណាស់មកហើយ។ គេបានពណ៌នាជំងឺនេះលើមនុស្សតាំងពីជាង៤ 000ឆ្នាំមុនមកម្ល៉េះ។***

ជំងឺនេះមានវត្តមានក្នុងគ្រប់ប្រទេសទាំងអស់ ប៉ុន្តែដោយសារមានថ្នាំបង្ការ គេកម្រឃើញជំងឺនេះណាស់នៅតាមប្រទេសអភិវឌ្ឍ។ នៅទូទាំងសកលលោក ជំងឺឆ្កែឆ្កួតបង្កឱ្យមានករណីស្លាប់ប្រហែល៦ម៉ឺននាក់ក្នុងមួយឆ្នាំ។ ភាគច្រើននៃករណីមនុស្សកើតជំងឺឆ្កែឆ្កួតស្ថិតនៅតាមសហគមន៍ជនបទក្នុងប្រទេសក្រីក្រ។ ដោយសត្វឆ្កែស្ទើរតែទាំងអស់មិនបានចាក់ថ្នាំបង្ការជំងឺឆ្កែឆ្កួត និងដោយមានចំនួនករណីឆ្កែខាំច្រើននាំឱ្យប្រទេសកម្ពុជាជាប្រទេសដែលប្រឈមនឹងជំងឺឆ្កែឆ្កួតញឹកញាប់។

ការសិក្សានានាក្នុងឆ្នាំ២០០៧ របស់វិទ្យាស្ថានប៉ាស្ទ័រកម្ពុជា បានប៉ាន់ប្រមាណថា មានករណីមនុស្សស្លាប់ដោយជំងឺឆ្កែឆ្កួតជាង៨00នាក់ក្នុងមួយឆ្នាំ។ រាប់ទាំងកុមារ និងមនុស្សធំ។ តួលេខនេះស្ថិតនៅក្នុងចំណោមតួលេខខ្ពស់បំផុតដែលគេបានបោះពុម្ពផ្សាយនៅលើសកលលោក។ ទោះជាមានប្រជាជនត្រឹមតែប្រមាណ១៦លាននាក់ ប្រទេសកម្ពុជាមានអ្នកស្លាប់ដោយជំងឺ



The boundaries and names shown and the designations
of any opinion whatsoever on the part of the World Heal
of any country, territory, city or area or of its authorities, o
or boundaries. Dotted lines on maps represent approxim
yet be full agreement. © WHO 2015. All rights reserved

ឆ្កែឆ្កួតដល់ទៅ១,៣%នៃចំនួនករណីស្លាប់សរុបដោយជំងឺនេះនៅទូទាំងសកលលោក ពោលគឺចំនួនមួយ អសមាមាត្រ បើគិតពីចំនួនប្រជាជន។

ទិន្នន័យពីវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា តាមរយៈការសិក្សាតាមភូមិនៅខេត្តសៀមរាបបានបង្ហាញថា ក្នុងមួយឆ្នាំ មានប្រជាជន១នាក់ក្នុងចំណោម២០នាក់ត្រូវបានសត្វឆ្កែខាំ ជួនកាលជារបួសធ្ងន់ទៀតផង។ ដូចនេះ អាចមានករណីសត្វឆ្កែខាំរវាងពី៦ម៉ឺនទៅ១លានករណីក្នុងមួយឆ្នាំ នៅទូទាំងប្រទេស។

**តើប្អូនដឹងទេ?**

*យុទ្ធនាការចាក់ថ្នាំបង្ការជំងឺឆ្កែឆ្កួតឱ្យសត្វឆ្កែទូទៅអាចកាត់ផ្តាច់ខ្សែចង្វាក់ចម្លងនៃជំងឺនេះបាន។ ជំងឺឆ្កែឆ្កួតលើមនុស្សអាចកាត់បន្ថយបានដោយយុទ្ធនាការចាក់ថ្នាំបង្ការលើសត្វឆ្កែ បើការចាក់ថ្នាំបង្ការរក្សាបានកម្រិតគ្របដណ្តប់៧០%នៃសត្វឆ្កែ រួមទាំងសត្វឆ្កែអនាថាផង។*




map do not imply the expression
concerning the legal status
the delimitation of its frontiers
for which there may not

Data Source: World Health Organization
Map Production: Control of Neglected Tropical Diseases (NTD)
World Health Organization

World Health Organization

ផែនទីបង្ហាញវត្តមានករណីជំងឺឆ្កែឆ្កួតចម្លងដោយសត្វឆ្កែនៅលើពិភពលោក ឆ្នាំ២០១០-២០១៤

## តើប្អូនដឹងទេ?

ស្បែករបស់យើងជារនាំងដែលមេរោគជំងឺឆ្កែឆ្កួតមិនអាចឆ្លងកាត់បានទេ។ មេរោគអាចឆ្លងចូលក្នុងខ្លួនយើងបានទាល់តែមានការខាំ ឬខ្វាច ឬលិឍលើរបួសថ្មីៗដោយសត្វដែលឈឺជំងឺឆ្កែឆ្កួត ឬដោយទឹកមាត់របស់វាចូលភ្នែក ច្រមុះ ឬមាត់របស់យើង ឬតាមរយៈការប៉ះពាល់ឆ្កែឆ្កួត។

## រោគសញ្ញាជំងឺឆ្កែឆ្កួតលើមនុស្ស

វីរុសជំងឺឆ្កែឆ្កួតបង្កជំងឺលើប្រព័ន្ធសរសៃប្រសាទ និងធ្វើឱ្យប៉ះពាល់ដំណើរការនៃប្រព័ន្ធនេះ។ វាមិនបង្កឱ្យមានឃើញជារបួសសាច់ខួរក្បាលទេ ប៉ុន្តែវាបង្អាក់ដំណើរការនៃកោសិកាប្រសាទ ជាពិសេសពពួកកោសិកាដែលសម្របសម្រួលចង្វាក់បេះដូង និងចង្វាក់ដកដង្ហើមរបស់មនុស្ស។

រោគសញ្ញាលេចឡើងក្នុងរវាងពី១ទៅ៣ខែបន្ទាប់ពីមានការឆ្លងវីរុសចូលក្នុងខ្លួន តាមមុខរបួសបង្កដោយសត្វដែលឈឺជំងឺឆ្កែឆ្កួត។ រោគសញ្ញាមានច្រើនសណ្ឋានរាប់តាំងពីភាពស្ពឹកស្រពន់រហូតដល់ការប្រកាច់កន្ត្រាក់តបទៅនឹងរំញោចនានា។

បដិសេធទទួលទានទឹក



រំញោចខ្លាំងពេលត្រូវខ្យល់



ហៀរទឹកមាត់



មនុស្សពេញវ័យ និងកុមារដែលឈឺជំងឺឆ្កែឆ្កួត អាចមានអាការៈស្ពឹកដៃជើង ផងខ្លួន និងការរលាកខួរក្បាល។ ជាញឹកញាប់រោគសញ្ញាចម្បងនៃជំងឺជាសញ្ញាផ្នែកប្រព័ន្ធប្រសាទ ជាពិសេសការថប់អារម្មណ៍ អន្ទះអន្ទែង ការពិបាកលេបអាហារ ពិបាកលេបទឹក(ជួនកាលដល់ថ្នាក់ខ្លាចទឹកក៏មានដែរ) ពេលខ្លះការប្រកាច់កន្ត្រាក់ភ្លោចដោយខ្យល់ផាត់មកលើ ក្លិន ឬពន្លឺ។ អ្នកជំងឺវិវឌ្ឍទៅរកការបាត់បង់ស្មារតីទាំងស្រុង និងស្លាប់ក្នុងរវាង២ទៅ៣ថ្ងៃភាគច្រើនដោយសារអ្នកជំងឺមិនអាចដកដង្ហើមបាន។ លទ្ធផលចុងក្រោយនៃជំងឺ ពេលមានស្តែងចេញជារោគសញ្ញា ហើយជានិច្ចកាល គឺជៀសមិនផុតពីស្លាប់ឡើយ។



ពិបាកដកដង្ហើម



## តើប្អូនដឹងទេ?

ប្រព័ន្ធប្រសាទរបស់យើងសាងសង់ពីកោសិកាប្រសាទតូចៗបង្កើតជាខួរក្បាល និងសរសៃប្រសាទ។ ខួរក្បាលជាអ្នកទទួល និងបញ្ជាសញ្ញារំញោច។ ចំណែកឯសរសៃប្រសាទជាអ្នកបញ្ជូនសញ្ញារំញោចទៅទូទាំងផងខ្លួនរបស់យើង។ ប្រព័ន្ធប្រសាទចែកចេញជាពីរផ្នែកគឺប្រព័ន្ធប្រសាទកណ្តាល(ខួរក្បាល និងខួរឆ្អឹងខ្នង) និងប្រព័ន្ធប្រសាទសាខាដែលតភ្ជាប់ប្រព័ន្ធកណ្តាលទៅទូទាំងតួខ្លួន។ តួនាទីនៃប្រព័ន្ធប្រសាទគឺធានាឱ្យមានការបញ្ជាចលនានានា ការទទួលដឹងសភាវៈនានា (ក្លិន សីតុណ្ហភាព រសជាតិ ជាដើម) និងការរក្សាដំណើរការធម្មតានៃសរីរាង្គខាងក្នុង(ក្រពះពោះវៀន បេះដូង សួតជាដើម)។ ក្រោយពេលឆ្លងចូលតាមមុខរបួសបង្កដោយសត្វ វីរុសជំងឺឆ្កែឆ្កួតមានចលនាទៅរក និងបន្ទាប់មក ចេញពីខួរក្បាល គឺឆ្លងកាត់តាមប្រព័ន្ធប្រសាទយើងនេះ។

# ហានិភ័យនៃជំងឺឆ្កែឆ្កួតនៅកម្ពុជា

### *វិទ្យាស្ថានប៉ាស្ទ័រកម្ពុជានៅទីក្រុងភ្នំពេញបានចាក់ថ្នាំបង្ការជំងឺឆ្កែឆ្កួតក្រោយសត្វខាំដល់ប្រជាជនប្រមាណ២ម៉ឺននាក់ក្នុងមួយឆ្នាំ។*

ទិន្នន័យពីមជ្ឈមណ្ឌលចាក់ថ្នាំបង្ការជំងឺឆ្កែឆ្កួតនៃវិទ្យាស្ថានប៉ាស្ទ័រ ក្នុងរវាងឆ្នាំ២០១៣-២០១៥ (ផែនទីខាងក្រោម សរុបអ្នកទទួលថ្នាំបង្ការ ៦៤ ១៥៨នាក់) បង្ហាញថា អ្នករងគ្រោះដោយសត្វឆ្កែខាំមាននៅគ្រប់ខេត្តក្រុងនៃប្រទេសកម្ពុជា ក្នុងនោះ៩០%នៅភ្នំពេញ និងតាមខេត្តជិត៧ភ្នំពេញ(កណ្ដាល កំពង់ស្ពឺ កំពង់ចាម ព្រៃវែង និងតាកែវ)។ ព័ត៌មាននេះមិនមានន័យថា នៅតាមខេត្តឆ្ងាយៗឯទៀត មានករណីឆ្កែខាំតិចតួច ឬមានហានិភ័យជំងឺឆ្កែឆ្កួតតិចតួចនោះទេ គឺដោយសារតែចម្ងាយផ្លូវឆ្ងាយ ការធ្វើដំណើរលំបាកក្នុងការទៅចាក់ថ្នាំបង្ការជំងឺឆ្កែឆ្កួតនៅភ្នំពេញ បានជាមានតួលេខតិចតួច។




ផែនទីបង្ហាញប្រភពអ្នកមកទទួលថ្នាំបង្ការជំងឺឆ្កែឆ្កួតក្រោយសត្វខាំ នៅវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា ឆ្នាំ២០១៣-២០១៥

# វត្តមាននៃជំងឺឆ្កែឆ្កួតនៅកម្ពុជា

***វិទ្យាស្ថានប៉ាស្ទ័រកម្ពុជាបានធ្វើតេស្តឃើញវត្តមានជំងឺឆ្កែឆ្កួតលើសត្វឆ្កែនៅតាមខេត្តនានាទូទាំងប្រទេសកម្ពុជា។***

មន្ទីរពិសោធន៍ផ្នែកវីរុសសាស្ត្រនៃវិទ្យាស្ថានប៉ាស្ទ័រកម្ពុជាបានធ្វើតេស្តសត្វឆ្កែ៣ ៧០៣ក្បាលដែលបានបង្ករបួសលើមនុស្សក្នុងរវាងឆ្នាំ១៩៩៨-២០១៦ និងបានរកឃើញចំនួនពាក់កណ្ដាលនៃសត្វឆ្កែទាំងនោះ(១៨៤២ក្បាលស្មើនឹង៥០%) មានវីរុសឆ្កែឆ្កួតក្នុងខួរក្បាល និងមានប្រភពមកពីគ្រប់ខេត្តក្រុងនៃប្រទេសកម្ពុជា នៅជិតក៏ដូចជានៅឆ្ងាយពីភ្នំពេញ រួមទាំងទីក្រុងភ្នំពេញផង(ផែនទីខាងក្រោម)។ ក្បាលសត្វឆ្កែដែលគេបានធ្វើតេស្តទាំងនោះត្រូវបានអ្នករងគ្រោះយកមកវិទ្យាស្ថានប៉ាស្ទ័រ នៅពេលដែលគាត់មកទទួលថ្នាំបង្ការជំងឺឆ្កែឆ្កួតក្រោយរងរបួស។




ផែនទីបង្ហាញប្រភពសត្វឆ្កែមានជំងឺឆ្កែឆ្កួតដែលបានធ្វើតេស្តវិជ្ជមាននៅវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា ឆ្នាំ១៩៩៨-២០១៦

## ការឆ្លងមេរោគឆ្កែឆ្កួតទៅមនុស្ស

មេរោគឆ្លងចូលតាមមុខរបួស និងមានចលនាតាមប្រព័ន្ធសរសៃប្រសាទសំដៅទៅបង្កោគនៅក្នុងខួរក្បាល ធ្វើឱ្យរលាកខួរក្បាល ស្តែងចេញជាជំងឺឆ្កែឆ្កួត។





❹មេរោគធ្វើដំណើរឡើងដល់ខួរក្បាល និងបង្កឱ្យមានការរលាកខួរក្បាល និងស្តែងចេញជាជំងឺឆ្កែឆ្កួត

❺មេរោគធ្វើដំណើរចេញទៅតាមក្រពេញនានា ក្នុងនោះមានក្រពេញទឹកមាត់របស់អ្នកជំងឺ


ជំងឺឆ្កែឆ្កួតអាចបង្ការបាន១០០%ដោយចាក់ថ្នាំបង្ការ
ខេត្តកំពង់ធំ - ថ្ងៃមួយ កុមារាម្នាក់អាយុ១១ឆ្នាំកំពុងដើរលេងក្នុងភូមិ។ គេមិនដឹងថា មានឆ្កែមួយក្បាលកំពុងដើរតាមពីក្រោយគេឡើយ...
អូយ! ម៉ែជួយផង ឆ្កែខាំ!
ដោយឮសម្រែក ម្ចាស់ឆ្កែក៏ចេញមកមើល។
ឆ្កែនេះស្ទួចងា មិនស្រួលទេ!
ហ៊ឺ! ហ៊ឺ!
កុំយំអីកូន! លោកគ្រូពេទ្យបានលាង និងរុំរបួសឱ្យកូនហើយ។ ម៉ែនឹងនាំកូនទៅចាក់ថ្នាំបង្ការជំងឺឆ្កែឆ្កួតតាមគ្រូពេទ្យប្រាប់។
ម្ចាស់ឆ្កែក៏បានជួយម្តាយកុមារនាំកុមាររងគ្រោះទៅចាក់ថ្នាំបង្ការជំងឺឆ្កែឆ្កួតនៅវិទ្យាស្ថានប៉ាស្ទ័រកម្ពុជានៅរាជធានីភ្នំពេញ ព្រមទាំងបានយកក្បាលឆ្កែទៅឱ្យមន្ទីរពិសោធន៍ប៉ាស្ទ័រពិនិត្យដែរ។


កូនបងប្រឈមនឹងជំងឺឆ្កែឆ្កួតហើយ។ ស៊ូទ្រាំ...
មន្ទីរពិសោធន៍បានពិនិត្យឃើញថា ខួរក្បាលឆ្កែនោះមានមេរោគជំងឺឆ្កែឆ្កួត។
ថ្ងៃនេះកូនបងបានទទួលថ្នាំបង្ការលើកទី១ហើយ។ ៣ថ្ងៃទៀត ត្រូវមកទទួលលើកទី២ និងណាត់បន្ត។ សរុបទាំងអស់មាន៤លើកទើបគ្រប់ ដើម្បីបង្ការជំងឺឆ្កែឆ្កួត។
៦ខែក្រោយ
ជម្រាបសួរបងស្រី ខ្ញុំទូរស័ព្ទពីផ្នែកបង្ការជំងឺឆ្កែឆ្កួតនៃវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា។ តើកូនបងដែលឆ្កែខាំ និងបានមកចាក់ថ្នាំបង្ការនោះ ឥឡូវមានសុខភាពល្អជាធម្មតាទេ?
ចាស លោកគ្រូ កូនខ្ញុំមានសុខភាពល្អធម្មតាទេ! អរគុណ!
ចាក់ថ្នាំបង្ការជំងឺឆ្កែឆ្កួត ក្រោយសត្វខាំឱ្យបានទាន់ពេលវេលា និងគ្រប់ចំនួនលើក ដើម្បីជៀសផុតពីគ្រោះថ្នាក់ដោយជំងឺឆ្កែឆ្កួត។

## តើប្អូនដឹងទេ?

*វីរុសជំងឺផ្ដាសាយបក្សីផុយស្រួយណាស់។ វាស្រោបដោយស្រទាប់ស្រោមជាតិខ្លាញ់ (លីពីដ)ដែលអាចបំផ្លាញបានយ៉ាងងាយដោយសាប៊ូ ថ្នាំសម្លាប់មេរោគ និង អាល់កុល។*

## តើត្រូវធ្វើអ្វីបន្ទាប់ពីមានរបួសដោយសត្វខាំ ឬខ្វាច?

*ក្នុងករណីសត្វខាំ ឬខ្វាច ហានិភ័យនៃការឆ្លងជំងឺផ្ដាសាយបក្សីអាស្រ័យលើស្ថានភាពសុខភាពរបស់សត្វនោះ(សុខភាពល្អ ឬឈឺ) លើបរិមាណវីរុសដែលអាចចូលក្នុងរបួស លើទីកន្លែងនៃខ្លួន លើទំហំនិងជម្រៅរបួស លើស្ថានភាពប្រព័ន្ធការពារខ្លួននៃអ្នករងគ្រោះ ក៏ដូចជាលើការបាន ឬមិនបានលាងសម្អាតមុខរបួសភ្លាមៗឱ្យបានស្អាតល្អ។ ការចាក់ថ្នាំបង្ការជំងឺផ្ដាសាយក្រោយសត្វខាំ ឬខ្វាចនាំឱ្យជៀសផុតពីជំងឺផ្ដាសាយយ៉ាងមានប្រសិទ្ធភាព។*

*កុំមើលរំលងរបួស ទោះជារបួសនោះតូចក៏ដោយ។ កុមារត្រូវប្រញាប់ប្រាប់ទៅមនុស្សធំ បើមានសត្វដែលមិនធ្លាប់ស្គាល់ខាំ ឬខ្វាច។*




ត្រូវប្រើសាប៊ូម្សៅ សាប៊ូទឹក ឬសាប៊ូដុំ




ត្រូវបង្ហូរ ឬចាក់ទឹកលាងឱ្យបានប្រមាណពី១០ទៅ១៥នាទី

ត្រូវប្រញាប់លាងសម្អាតរបួសដោយទឹកនិងសាប៊ូឱ្យបានស្អាត ដោយចាក់ទឹកបង្ហូរលាងឱ្យបានប្រមាណ១០ទៅ១៥នាទី។ បើមិនមានសាប៊ូ លាងតែជាមួយទឹកក៏បាន។

ត្រូវប្រើថ្នាំសម្លាប់មេរោគ ដូចជាទឹកថ្នាំបេតាឌីន ឬអាល់កុល ដើម្បីសម្អាតរបួស។

ត្រូវទៅជួបពិគ្រោះជាមួយគ្រូពេទ្យអំពីការបង្ការជំងឺឆ្កែឆ្កួតឱ្យបានឆាប់បំផុត ដើម្បីទទួលបានការចាក់ថ្នាំបង្ការជំងឺឆ្កែឆ្កួត និងថ្នាំផ្សេងទៀតដែលចាំបាច់។

មិនត្រូវដេរមុខរបួសទេ បើអាចជៀសវាងបាន គឺគ្រាន់តែរុំគ្របស្រាលៗលើមុខរបួស ដើម្បីឱ្យមុខរបួសត្រូវខ្យល់បានច្រើន។

### តើប្អូនដឹងទេ?

ការប្រើប្រាស់វិធីថែទាំបុរាណលើមុខរបួសបង្កដោយសត្វឆ្កែ ឬសត្វដទៃ មិនមែនជាការត្រឹមត្រូវតាមគោលការណ៍ថែទាំរបួសនោះទេ។

មិនត្រូវប្រើបាយកក ម្ទេស សម្បុកពីងពាង ខ្ទឹមស ប្រហុក ក្រូចឆ្មារ ស្ពោះផ្ទុំ ឬវិធីបុរាណផ្សេងៗទៀតទេ។

សំខាន់បំផុតត្រូវលាងសម្អាតរបួសក្នុងគោលបំណងឱ្យទឹកមាត់សត្វ ក៏ដូចជាមេរោគចេញ និងងាប់អស់ពីមុខរបួសដោយប្រើទឹកស្អាត សាប៊ូ និងថ្នាំសម្លាប់មេរោគ។






ត្រូវប្រើអាល់កុល ឬបេតាឌីន ដើម្បីសម្អាតមេរោគ



ការចាក់សើស្បែក
Injection intradermique (ID)
ក្នុងស្រទាប់ខៃមនៃស្បែក

### តើប្អូនដឹងទេ?

ប្អូននៅមានឱកាសចាក់ថ្នាំបង្ការជំងឺឆ្កែឆ្កួត ក្រោយពេលដែលសត្វខាំ ឬខ្វាច ដោយសារវីរុសជំងឺឆ្កែឆ្កួតប្រើរយៈពេលវែង ច្រើនសប្តាហ៍ ដើម្បីធ្វើដំណើរទៅបង្ករោគនៅខួរក្បាល។ ប៉ុន្តែប្អូនមិនត្រូវរង់ចាំទេ ក្រោយពេលមានសត្វខាំ ឬខ្វាច ប្អូនត្រូវប្រញាប់ទៅរកចាក់ថ្នាំបង្ការជំងឺឆ្កែឆ្កួត។ ក្រោយពេលចាក់ថ្នាំបង្ការទាន់ពេលវេលា ខ្លួនរបស់ប្អូនមានពេលគ្រប់គ្រាន់ក្នុងការផលិតប្រព័ន្ធការពារខ្លួនកម្ចាត់វីរុស មិនឱ្យទៅដល់ខួរក្បាលបាន។

## ការចាក់ថ្នាំបង្ការជំងឺឆ្កែឆ្កួតក្រោយពេលមានសត្វខាំ ឬខ្វាច

បន្ទាប់ពីមានរបួសដោយសត្វខាំ ឬខ្វាច យើងត្រូវស្វែងរកការចាក់ថ្នាំបង្ការជំងឺឆ្កែឆ្កួត ដូចយ៉ាងជាវិទ្យាស្ថានប៉ាស្ទ័រកម្ពុជានៅភ្នំពេញ ឬមជ្ឈមណ្ឌលណាផ្សេងទៀតនៅតាមខេត្ត។

ការចាក់ថ្នាំបង្ការជំងឺឆ្កែឆ្កួតក្រោយសត្វខាំ ឬខ្វាចត្រូវធ្វើឡើងចំនួន ៤លើក ដើម្បីទទួលបានការការពារប្រកបដោយប្រសិទ្ធភាព។ គ្រូពេទ្យអាចផ្តល់នូវថ្នាំអ៊ីមុយណូគ្លោប៊ុយលីន(Immunoglobuline) បន្ថែមទៀតទៅតាមភាពធ្ងន់ធ្ងរនៃរបួស ឬលទ្ធផលវិជ្ជមាននៃការធ្វើតេស្តខួរក្បាលសត្វ។

ការចាក់ថ្នាំបង្ការទាំង៤លើក ដោយចាក់សាច់ដុំ ឬចាក់សើស្បែក៖

លើកទី១៖ ថ្ងៃចាក់លើកដំបូង

លើកទី២៖ នៅ៣ថ្ងៃក្រោយចាក់លើកទី១

លើកទី៣៖ នៅ៧ថ្ងៃក្រោយចាក់លើកទី១

លើកទី៤៖ នៅ២១ ឬ២៨ថ្ងៃក្រោយចាក់លើកទី១

បើអ្នកធ្លាប់បានចាក់ថ្នាំបង្ការជំងឺឆ្កែឆ្កួតគ្រប់ចំនួនលើកពីមុនមក អ្នកត្រូវទទួលថ្នាំបង្ការជាថ្មីតែ២លើកប៉ុណ្ណោះ ក្រោយពេលសត្វខាំ ឬខ្វាចជាថ្មីទៀត គឺលើកទី១ និងលើកទី២។

## ការចាក់ថ្នាំបង្ការជំងឺឆ្កែឆ្កួតមុនពេលមានសត្វខាំ

យើងក៏អាចចាក់បង្ការជាមុនបានដែរ ដោយមិនចាំបាច់ទាល់តែរងរបួសដោយសត្វខាំ ឬខ្វាចនោះទេ។ ពោលគឺជាការការពារខ្លួនជាមុនហើយបន្ទាប់ពីនោះ បើមានសត្វខាំ ឬខ្វាច យើងគ្រាន់តែត្រូវការចាក់ថ្នាំបង្ការរំឭកចំនួនតែ២លើកប៉ុណ្ណោះ ពុំចាំបាច់ត្រូវចាក់៤លើកនោះទេ។

ការចាក់ថ្នាំបង្ការជំងឺឆ្កែឆ្កួតមុនសត្វខាំ ឬខ្វាចត្រូវការចាក់ចំនួន៣លើក ៖

លើកទី១ ៖ ថ្ងៃចាក់លើកដំបូង

លើកទី២ ៖ នៅ៧ថ្ងៃក្រោយចាក់លើកទី១

លើកទី៣ ៖ នៅ២១ ឬ២៨ថ្ងៃក្រោយចាក់លើកទី១។



### តើប្អូនដឹងទេ?

ការចាក់ថ្នាំបង្ការជំងឺឆ្កែឆ្កួតមិនមែនចាក់តែមួយលើកអាចបង្ការបានមួយជីវិតនោះទេ។ ដើម្បីធានាថា ប្អូនគេចផុតពីជំងឺដ៏គ្រោះថ្នាក់នេះ ប្អូនត្រូវលាងសម្អាតរបួស និងប្រញាប់ទៅពិគ្រោះជាមួយគ្រូពេទ្យជានិច្ច រាល់ពេលមានរបួសបង្កដោយសត្វ ទោះជាប្អូនធ្លាប់បានទទួលការចាក់ថ្នាំបង្ការជំងឺនេះពីមុនមកក៏ដោយ។ គ្រូពេទ្យនឹងណែនាំថា តើប្អូនចាំបាច់ត្រូវចាក់ថ្នាំបង្ការជំងឺឆ្កែឆ្កួតជាថ្មី ឬមិនចាំបាច់។

ការចាក់សាច់ដុំ
Injection intramusculaire (IM)
ទៅក្នុងស្រទាប់សាច់ដុំ

# ធ្វើយ៉ាងណាជៀសវាងសត្វឆ្កែខាំ

***បើគ្រួសាររបស់ប្អូនទទួលយកឆ្កែមកចិញ្ចឹមក្នុងផ្ទះ គួរតែមានការអនុវត្តចំណុចមួយចំនួនដូចជា៖***

- បង្រៀនឆ្កែឱ្យចេះស្គាល់ម្ចាស់ ដោយចំណាយពេលនៅជាមួយវា
- បង្ហាត់ឆ្កែឱ្យស៊ាំនឹងវត្តមានរបស់មនុស្សដទៃក្រៅពីម្ចាស់
- ក្រៀវវា(ក្រៅពីកុំឱ្យវាមានកូន ជាទូទៅនាំឱ្យកាត់បន្ថយចរិតកាចរបស់ឆ្កែដែរ)
- មិនត្រូវទៅជិតឆ្កែដែលប្អូនមិនដែលស្គាល់ជាដាច់ខាត
- មិនត្រូវទៅលេងជាមួយឆ្កែ ដោយមិនមានមនុស្សធំនៅក្បែរនោះទេ។

**តើប្អូនដឹងទេ?**

ប្អូនត្រូវប្រាប់ទៅមនុស្សធំ ឬទៅពេទ្យសត្វ ឬអ្នកបង្ហាត់សត្វភ្លាម នៅពេលដែលប្អូនឃើញថា ឆ្កែរបស់ប្អូនបង្ហាញនូវអាការៈកាចខុសធម្មតា ឬបញ្ចេញនូវចរិតខុសពីអ្វីដែលប្អូនធ្លាប់ស្គាល់។ ប្អូនត្រូវប្រុងប្រយ័ត្ន និងត្រូវនៅឆ្ងាយពីឆ្កែនោះ ជៀសវាងរងរបួសដោយវាខាំ។



ត្រូវនៅឱ្យស្ងៀមមួយកន្លែង(ដូចរូបចម្លាក់) បើមានឆ្កែដែលប្អូនមិនស្គាល់ ចូលមកជិតប្អូន



ត្រូវចាក់ថ្នាំបង្ការសត្វឆ្កែប្រឆាំងនឹងជំងឺឆ្កែឆ្កួត



មិនត្រូវទុកកុមារតូចឱ្យនៅតែឯងជាមួយសត្វឆ្កែនោះទេ



នៅពេលឃើញឆ្កែ មិនត្រូវស្រែក យំ ឬរត់លឿនចេញពីវានោះទេ ព្រោះធ្វើបែបនេះបណ្តាលឱ្យវាភ័យ និងអាចស្ទុះមកខាំ



បើឆ្កែកន្ត្រាងប្អូនដួល ប្អូនត្រូវសំងំមួយកន្លែង ដេកចំហៀង
ចំកោងខ្នង ឱបក្បាលជង្គង់ ការពារមុខប្អូនកុំឱ្យឆ្កែខាំមុខ



ប្អូនត្រូវប្រាប់ទៅមនុស្សធំភ្លាម បើឃើញមានឆ្កែប្លែកមុខ
ឬឆ្កែដែលមានលក្ខណៈខុសពីធម្មតា



មេឆ្កែការកូនណាស់ មិនត្រូវទៅលេងកូនឆ្កែទើបនឹងកើតនោះទេ



ត្រូវទុកពេលឱ្យឆ្កែស្គាល់ និងហិតក្លិនដៃរបស់ប្អូនសិន
មុននឹងទៅស្ទាបអង្អែលវាលេង



មិនត្រូវទៅរំខានឆ្កែដែលកំពុងដេកទេ



មិនត្រូវទៅរំខាន ឬទាញយកចំណីចេញ ពេលដែលឆ្កែកំពុងស៊ីទេ



កុំសម្លឹងចំៗភ្នែកឆ្កែ ជាពិសេសកុំបង្ហាញក្រសែភ្នែកកាច សម្លក់ដាក់សត្វឆ្កែ

**តើប្អូនដឹងទេ?**

*សត្វដែលបានក្រៀវរួច មានចរិតស្លូត និងស្ងប់ស្ងាត់ជាងសត្វដែលមិនក្រៀវ ដោយសារការក្រៀវយកក្រពេញបន្តពូជចេញ ក្នុងគោលដៅមិនឱ្យមានកូនបាននាំឱ្យថយចុះអ័រម៉ូនភេទ។*

# ការចាក់ថ្នាំបង្ការឱ្យសត្វឆ្កែ

***ការចាក់ថ្នាំបង្ការជំងឺឆ្កែឆ្កួតឱ្យសត្វឆ្កែអាចឈានទៅលុបបំបាត់ជំងឺឆ្កែឆ្កួតក្នុងប្រទេសកម្ពុជាបាន។***

*ជំងឺឆ្កែឆ្កួតលើសត្វឆ្កែជាជំងឺមួយគ្រោះថ្នាក់បំផុត ដោយហេតុថាជំងឺនេះឆ្លងទៅមនុស្ស និងសត្វដទៃតាមការខាំ ឬខ្វាច។ ចាក់ថ្នាំបង្ការជំងឺឆ្កែឆ្កួតឱ្យឆ្កែរបស់ខ្លួនគឺជាការការពារដ៏ល្អបំផុត ទាំងសម្រាប់សត្វឆ្កែ ទាំងសម្រាប់មនុស្ស។*

*ថ្នាំបង្ការនឹងនាំឱ្យសត្វឆ្កែរបស់អ្នកបង្កើតនូវប្រព័ន្ធការពារខ្លួនប្រឆាំងវីរុស។ បើឆ្កែនោះត្រូវបានខាំដោយឆ្កែដទៃទៀត ឆ្កែរបស់អ្នកនឹងមិនឈឺ ហើយក៏មិនអាចចម្លងជំងឺទៅមនុស្សបានដែរ។*

*ការចាក់ថ្នាំបង្ការឱ្យសត្វឆ្កែអាចធ្វើនៅគ្លីនិកសត្វ ឬនៅតាមយុទ្ធនាការចាក់ថ្នាំបង្ការណាមួយ។ គេអាចចាក់លើកដំបូង នៅពេលឆ្កែមានអាយុបាន៣ខែ។ ជាការចាក់ក្រោមស្បែក មិនធ្វើឱ្យឈឺចាប់ទេ និងមិនបង្កជាជំងឺដល់សត្វឆ្កែទេ។ ជាឧទាហរណ៍ជាក់ស្តែង ដោយមានការចាក់ថ្នាំបង្ការលើសត្វឆ្កែ ចំនួនករណីមនុស្សស្លាប់ដោយជំងឺឆ្កែឆ្កួតបានថយចុះយ៉ាងច្រើននៅក្នុងប្រទេសមួយចំនួន ពេលខ្លះ គឺកាត់បន្ថយដល់សូន្យករណី។ នៅប្រទេសថៃ នាឆ្នាំ១៩៨០ គេរកឃើញមានអ្នកស្លាប់ដោយជំងឺឆ្កែឆ្កួតចំនួន៣៧០ករណី។ រហូតដល់ឆ្នាំ១៩៩០ ជំងឺនេះបន្តបណ្តាលឱ្យមានមនុស្សស្លាប់២០០ករណីក្នុង១ឆ្នាំ។ ការសិក្សាមួយបានបង្ហាញថា មានតែ១៥% នៃកូនឆ្កែប៉ុណ្ណោះបានទទួលថ្នាំបង្ការ*



ជំងឺឆ្កែឆ្កួត និង៦០%នៃករណីមនុស្សស្លាប់ដោយជំងឺនេះបង្កដោយការខាំរបស់កូនឆ្កែអាយុតិចជាង៣ខែ។ នៅឆ្នាំ១៩៩២ មានច្បាប់មួយតម្រូវឱ្យចាក់ថ្នាំបង្ការលើគ្រប់សត្វឆ្កែ និងសត្វឆ្មាអាយុចាប់ពី៣ខែឡើងទៅ។ តាមរយៈការចាក់ថ្នាំបង្ការទ្រង់ទ្រាយធំបែបនេះ និងតាមកម្មវិធីផ្សព្វផ្សាយព័ត៌មានដល់ប្រជាជន គេបានរកឃើញមនុស្សស្លាប់ដោយជំងឺឆ្កែឆ្កួតតែ៨ករណីប៉ុណ្ណោះនៅឆ្នាំ២០០៨ ក្នុងប្រទេសថៃ។

នៅប្រទេសបង់ក្លាដេស ដោយមានសេវាបង្ការក្រោយសត្វខាំ ការចាក់ថ្នាំបង្ការទ្រង់ទ្រាយធំលើសត្វឆ្កែ និងវត្តមានកើនឡើងនៃថ្នាំបង្ការ ចំនួនករណីមនុស្សស្លាប់ដោយជំងឺឆ្កែឆ្កួតបានថយចុះ៥០% ក្នុងរវាងឆ្នាំ២០១០ដល់២០១៣។

**តើប្អូនដឹងទេ?**

នៅក្នុងប្រទេសកម្ពុជា មានសត្វឆ្កែភាគតិចណាស់ដែលបានចាក់ថ្នាំបង្ការជំងឺឆ្កែឆ្កួត។ យ៉ាងណាមិញ ថ្នាំបង្ការជំងឺឆ្កែឆ្កួត សម្រាប់សត្វឆ្កែ ឬឆ្មា មានវត្តមាន និងអាចរកបាននៅតាមមន្ទីរបសុព្យាបាលមួយចំនួន។

ការចាក់ថ្នាំបង្ការជំងឺឆ្កែឆ្កួតលើសត្វឆ្កែក្នុងយុទ្ធនាការសាកល្បងនៅខេត្តកណ្តាល



## តើប្អូនដឹងទេ?

នៅលើជញ្ជាំងប្រាសាទអង្គរវត្ត មានចម្លាក់រូបសត្វឆ្កែឈរជាជួរ មានរបៀបរៀបរយ បញ្ជាក់ថា ជាសត្វដែលគេបង្វឹកប្រើជាប្រយោជន៍បាន។

# យល់ដឹងបន្ថែមពីអតីត និងអនាគត

***សត្វឆ្កែត្រូវបានមនុស្សផ្សាំងយកមកចិញ្ចឹមតាំងពីជាង១២ ០០០ ឆ្នាំមុនមកម្ល៉េះ។***

## មនុស្ស និងសត្វឆ្កែ

ឯកសារបុរាណនានា(បន្ទះដីឥដ្ឋចារឹកជនជាតិស៊ូមែរ)ដែលគេរកឃើញនៅទីតាំងបច្ចុប្បន្នជាប្រទេសអ៊ីរ៉ាក់ បង្ហាញថា មនុស្សជំនាន់នោះស្គាល់ជំងឺឆ្កែឆ្កួត និងខ្លាចរអាតាំងពី៤០០ឆ្នាំមុននោះទៅទៀត។



រូបចម្លាក់ឆ្កែនៅថែវប្រាសាទអង្គរវត្ត

នៅប្រទេសកម្ពុជា ការចិញ្ចឹមឆ្កែប្រោកដជាត្រូវបានប្រជាជនអនុវត្តតាំងពីយូរលង់ណាស់មកហើយ។ យើងអាចឃើញរូបចម្លាក់ឆ្កែនៅលើថែវប្រាសាទអង្គរវត្ត និងវត្តមានតួអង្គឆ្កែក្នុងអត្ថបទជាសាច់រឿងសាសនា(ឧទាហរណ៍ រឿងព្រះវេស្សន្តរ) ក៏ដូចជាសាច់រឿងព្រេងនិទាននានាដែលមានអាយុកាលយូរលង់ណាស់មកហើយ។ យ៉ាងណាមិញ ក្នុងចំណោមឆ្នាំទាំង១២នៃរាសីចក្រមានឆ្នាំចតំណាងដោយឆ្កែដែលសរបញ្ជាក់ឱ្យឃើញកាន់តែច្បាស់អំពីសារៈសំខាន់នៃឆ្កែ និងទំនាក់ទំនងតាំងពីយូរអង្វែងរវាងមនុស្សនិងឆ្កែ។

## តើប្អូនដឹងទេ?

រឿងព្រះវេស្សន្តរមានក្នុងគម្ពីរព្រះពុទ្ធសាសនា និងមានពណ៌នាជារូបភាពតាមអារាមនានា តំណាលពីតាព្រាហ្មណ៍ជូជក់ អាស្រ័យចិញ្ចឹមជីវិតតែនឹងដើរសុំទានគេ។ សម័យថ្ងៃមួយ តាជូជក់ត្រាច់ចរឆ្លងព្រៃក្នុងគោល-បំណងទៅរកសុំទានយកអ្នកបម្រើទៅឱ្យបម្រើប្រពន្ធក្មេងរបស់ខ្លួន។ ខណៈមួយនោះ តាជូជក់ត្រូវឆ្កែប្រមាញ់របស់ព្រានព្រៃដេញខាំ រត់ឡើងដើមឈើយកតែរួចជីវិត។



រូបស៊ីម៉ងត៍ក្នុងវត្តមួយនៅកោះដាច់បរិយាយពីតាជូជក់គេចពីសត្វឆ្កែ និងព្រានព្រៃ ក្នុងរឿងព្រះវេស្សន្តរ



រូបចម្លាក់លោក ល្វីស៍ ប៉ាស្ទ័រ នៅវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា

## លោក ល្វីស៍ ប៉ាស្ទ័រ និងការបង្កើតថ្នាំបង្ការជំងឺឆ្កែឆ្កួត

*លោក ល្វីស៍ ប៉ាស្ទ័រ* (Louis Pasteur) *កើតនៅថ្ងៃទី៧ ខែធ្នូ ឆ្នាំ ១៨២២ នៅក្រុងដូល ប្រទេសបារាំង។ ឆ្លងកាត់អាជីពជាអ្នកស្រាវជ្រាវវិទ្យាសាស្ត្រដ៏ជោគជ័យ និងការរកឃើញជាច្រើន គាត់បានសម្រេចចិត្តនៅឆ្នាំ១៨៨០(នៅអាយុ៥៨ឆ្នាំ) បង្កើតថ្នាំបង្ការមួយប្រឆាំងជំងឺឆ្កែឆ្កួតដែលជាជំងឺគួរឱ្យខ្លាច សម្លាប់ប្រជាជនជាច្រើន ហើយកាលនោះ គេមិនទាន់ដឹងវិធីការពារខ្លួនទប់ទល់នឹងជំងឺនេះនៅឡើយ។*

*លោក ល្វីស៍ ប៉ាស្ទ័រ ដែលធ្វើការនៅទីក្រុងប៉ារីស ប្រទេសបារាំង ចាប់ផ្តើមដំបូងដោយកំណត់រកវីរុសជំងឺឆ្កែឆ្កួត ដោយប្រើមីក្រូទស្សន៍ តែមិនបានសម្រេច ដោយវីរុសនោះតូចខ្លាំងណាស់។*

*ជាការពិត កម្រិតមើលឃើញនៃមីក្រូទស្សន៍នាសម័យនោះមិនអនុញ្ញាតឱ្យយើងមើលឃើញវីរុសបានទេ(គេទើបតែអាចមើលឃើញវីរុសជំងឺឆ្កែឆ្កួតជាលើកដំបូង នៅ១សតវត្សក្រោយមកទៀត គឺនៅឆ្នាំ១៩៦២ ដោយគេបានបង្កើតមីក្រូទស្សន៍អេឡិចត្រូនិក)។*

*លោក ល្វីស៍ ប៉ាស្ទ័រ និងសហការី ជាពិសេស លោក អេមីល រូ* (Emile Roux) *បានចាប់ផ្តើមស្រាវជ្រាវ និងពិសោធនៅលើសត្វជាលើកដំបូង ដូចជាសត្វឆ្កែ និងទន្សាយជាដើម។ គោលគំនិតគឺប្រែក្លាយវីរុសដែលបង្កជំងឺឱ្យទៅជាវីរុសដែលភ្ញោចប្រព័ន្ធការពារខ្លួនលើសត្វទន្សាយដោយមិនធ្វើឱ្យសត្វនោះឈឺងាប់។ ការភ្ញោចបង្កើតប្រព័ន្ធការពារខ្លួននឹងជួយការពារសត្វនោះប្រឆាំងជំងឺឆ្កែឆ្កួត។ ដើម្បីទទួលបានវីរុសដែលមិនធ្វើឱ្យសត្វឈឺងាប់(វីរុសខ្សោយ) គាត់បានទុកសរសៃខួរឆ្អឹងខ្នងទន្សាយដែលមានវីរុសបង្កជំងឺ ហាលចោលប៉ុន្មានថ្ងៃសិន មុននឹងយកសរសៃខួរនោះទៅកិនឱ្យម៉ត់ និងចាក់ឱ្យទន្សាយដែលគ្មានជំងឺ។ វិធីនេះនាំឱ្យលោក ប៉ាស្ទ័រ ទទួលបាន*

គំនូរលោក ល្វីស៍ ប៉ាស្ទ័រកំពុងកត់ត្រាការពិសោធថ្នាំបង្ការជំងឺឆ្កែឆ្កួតលើសត្វទន្សាយរវាងឆ្នាំ១៨៨៤



វីរុសដែលមិនបង្កជំងឺ តែផ្ទុយទៅវិញ ជាវីរុសដែលភ្ញោចបង្កើតប្រព័ន្ធការពារខ្លួន ការពារសត្វទន្សាយពីជំងឺឆ្កែឆ្កួត។

នៅឆ្នាំ១៨៨៣ ថ្នាំបង្ការជំងឺឆ្កែឆ្កួតត្រូវបានបង្កើត ក៏ប៉ុន្តែត្រូវឆ្លងកាត់ការសាកល្បងលើមនុស្សបន្ថែមទៀត។ ពេលនោះ លោក ល្វីស៍ ប៉ាស្ទ័រ រារែក! នាព្រឹកថ្ងៃទី៦ ខែកក្កដា ឆ្នាំ១៨៨៥ លោក ប៉ាស្ទ័រត្រូវតែសម្រេចចិត្តសាកល្បងថ្នាំបង្ការនោះលើមនុស្ស។ កុមារាម្នាក់អាយុ៩ឆ្នាំឈ្មោះ ស៊ូសេហ្វ មេយស្ទ័រ (Joseph Meister) បានត្រូវសត្វឆ្កែឆ្កួតខាំ១៤កន្លែង។ លោក ប៉ាស្ទ័រ និងក្រុមការងាររបស់គាត់បានសម្រេចចិត្តចាក់ថ្នាំបង្ការឱ្យកុមារនោះ ដើម្បីបញ្ចៀសមរណភាពដែលកុមារនោះប្រឈមយ៉ាងពិតប្រាកដ។ កុមារ ស៊ូសេហ្វ បានទទួលការចាក់ម្សៅខួរទន្សាយដែលមានវីរុសខ្សោយសរុប១៣លើក។ ការចាក់ថ្នាំបង្ការលើមនុស្សលើកទីមួយនេះ គឺជាជោគជ័យមួយ ៖ កុមារ ស៊ូសេហ្វ មិនបានឈឺជំងឺឆ្កែឆ្កួតឡើយ និងក្លាយជាមនុស្សទីមួយដែលបានទទួលថ្នាំបង្ការជំងឺឆ្កែឆ្កួត។ នៅខែកញ្ញា ឆ្នាំ១៨៨៥ កុមារម្នាក់ទៀត ឈ្មោះ ស៊ង់បាបទីស ស៊ុពីយ (Jean-Baptiste Jupille) ជាកុមារឃ្វាលចៀម អាយុ១៥ឆ្នាំ និងកុមារឃ្វាលចៀម៦នាក់ផ្សេងទៀតបានត្រូវសត្វឆ្កែឆ្កួតខាំយ៉ាងធ្ងន់ធ្ងរ។ ពេលនោះ លោក ប៉ាស្ទ័រ អនុវត្តការចាក់ថ្នាំបង្ការជាលើកទី២ ដោយទទួលបានជោគជ័យដូចលើកទី១ដែរ។ គឺចាប់តាំងពីថ្ងៃនោះហើយ ដែលការចាក់ថ្នាំបង្ការជំងឺឆ្កែឆ្កួតបានអភិវឌ្ឍនៅទូទាំងសកលលោក។




គំនូរក្នុងទស្សនាវដ្ដី La République Illustrée ឆ្នាំ១៨៨៦ បង្ហាញពីការចាក់ថ្នាំបង្ការជំងឺឆ្កែឆ្កួតឱ្យកុមារស៊ុពីយ ដោយមានវត្តមានលោក ល្វីស៍ ប៉ាស្ទ័រ

## តើប្អូនដឹងទេ?

តើថ្នាំបង្ការដំណើរការយ៉ាងដូចម្ដេច?

ថ្នាំបង្ការនាំយកបំណែកនៃមេរោគណាមួយទៅឱ្យជួបជាមួយរាងកាយមនុស្ស នាំឱ្យមានការភ្ញោចបង្កើតប្រព័ន្ធការពារខ្លួនជាមធ្យោបាយធម្មជាតិប្រឆាំងនឹងមេរោគនោះ។

ពេលរាងកាយជួបមេរោគនោះជាថ្មី រាងកាយស្គាល់ និងកម្ទេចចោលបាន។

រាងកាយរបស់យើងត្រូវការរយៈពេលច្រើនថ្ងៃ ដើម្បីផលិតប្រព័ន្ធការពារទាំងនេះក្រោយពេលចាក់ថ្នាំបង្ការ។

### តើប្អូនដឹងទេ?

ថ្នាំបង្ការជំងឺឆ្កែឆ្កួតជំនាន់ដំបូងជាថ្នាំបង្ការមានប្រសិទ្ធភាព ប៉ុន្តែមានការពិបាកក្នុងការប្រើ និងមិនមានសុវត្ថិភាពខ្ពស់ទេ។ គេត្រូវចាក់នៅក្បាលពោះ និងត្រូវចាក់ជាច្រើនថ្ងៃជាប់ៗគ្នា(ពី២ទៅ៣សប្តាហ៍) ទើបគ្រប់កម្រិត។ ថ្នាំបង្ការជំនាន់នោះផលិតពីខួរឆ្អឹងខ្នងសត្វដែលអាចបង្កជាប្រតិកម្មថ្នាំពេលចាក់នៅលើមនុស្ស។

## ការវិវឌ្ឍនៃថ្នាំបង្ការជំងឺឆ្កែឆ្កួត និងការចាក់ថ្នាំបង្ការ

ប្អូនមានសំណាងហើយ ដោយថ្នាំបង្ការបច្ចុប្បន្ន ត្រូវចាក់តែ៤លើកប៉ុណ្ណោះ។ ប៉ុន្តែ ការចាក់ថ្នាំបង្ការជំងឺឆ្កែឆ្កួតកាលពីអតីតកាលមិនងាយស្រួលដូចនេះទេ។

ថ្នាំបង្ការដែលលោក ប៉ាស្ទ័រ ប្រើជាលើកទី១កាលពីជាង១៣០ឆ្នាំមុន គឺនៅឆ្នាំ១៨៨៥ លើកុមារ ស៊ូសេហ្វ មេយស្ទ័រ ជាការចាក់ចំនួន ១៣ដងនូវសារធាតុយកចេញពីសរសៃខួរឆ្អឹងខ្នងទន្សាយដែលមានផ្ទុកវីរុសខ្សោយ។

ថ្នាំបង្ការប្រភេទនោះត្រូវបានគេប្រើជាលើកដំបូងនៅទ្វីបអឺរុប។ ក្រោយមក ដោយមានលោក អាល់ប៊ែរ កាល់ម៉ែត (Albert Calmette) នៅវិទ្យាស្ថានប៉ាស្ទ័រសៃហ្គន សម្រាប់ប្រទេសកម្ពុជា វៀតណាម និងឡាវ បានទទួលយកមកប្រើប្រាស់មុនប្រទេសផ្សេងៗនៅអាស៊ី នៅអាហ្វ្រិក ឬនៅអាមេរិកទៅទៀត។

ចាប់ពីឆ្នាំ១៩១១មក ថ្នាំបង្ការថ្មីមួយប្រភេទទៀតផលិតនៅប្រទេសឥណ្ឌាចេញពីខួរក្បាលសត្វចៀម ឬពពែមានផ្ទុកវីរុសជំងឺឆ្កែឆ្កួត



ឈុតសម្តែងបង្ហាញការថ្នាំបង្ការជំងឺឆ្កែឆ្កួតនៅលើពោះ ដោយប្រើថ្នាំបង្ការជំនាន់ដំបូង

ដែលធ្វើឱ្យខ្សោយដោយជាតិហ្វេណុល ត្រូវបានគេប្រើប្រាស់យ៉ាងទូលំទូលាយនៅអាស៊ីអាគ្នេយ៍ និងក្នុងពិភពលោក។ របៀបចាក់គឺចាក់នៅត្រង់ក្បាលពោះមួយម្ជុលក្នុងមួយថ្ងៃរយៈពេល២ទៅ៣សប្តាហ៍ជាប់គ្នា។ អ្នកទទួលថ្នាំបង្ការត្អូញត្អែរយ៉ាងខ្លាំងថា ចាក់ថ្នាំបង្ការនេះឈឺណាស់។

នៅឆ្នាំ១៩៤៨ គេបានផលិតថ្នាំបង្ការប្រភេទថ្មីទៀតចេញពីស៊ុតមាន់ ឬទាដែលមានដាក់វីរុសចូល។

ចាប់ពីឆ្នាំ១៩៦៤មក មានការរីកចម្រើនដ៏លឿនមួយក្នុងការផលិតថ្នាំបង្ការ។ គេងាកមកបណ្តុះកោសិកាវីរុសសុទ្ធៗនៅមន្ទីរពិសោធន៍ដើម្បីយកវីរុសសម្រាប់ផលិតជាថ្នាំបង្ការ។ ថ្នាំបង្ការអាចផលិតក្នុងបរិមាណច្រើនជាងមុន និងសុទ្ធជាងមុន បានជាគេត្រូវការចាក់តិចផងជាងមុន។

គឺថ្នាំបង្ការប្រភេទនេះហើយដែលគេកំពុងប្រើប្រាស់នាពេលបច្ចុប្បន្ននេះ ជាពិសេសនៅវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា។

## តើប្អូនដឹងទេ?

ថ្នាំបង្ការជំងឺឆ្កែឆ្កួតសម័យបច្ចុប្បន្ន មានប្រសិទ្ធភាព និងសុវត្ថិភាពខ្ពស់ ផលិតដោយបច្ចេកទេសទំនើប មិនប្រើខួរឆ្អឹងខ្នងសត្វទៀតទេ។ គេចាក់នៅស្មា ដោយចាក់ចូលក្នុងសាច់ដុំ ឬចាក់នៅស្រទាប់ស្បែក ចាក់ចំនួនតិចលើកជាងមុន និងប្រើកម្រិតថ្នាំបង្ការកាន់តែតិចជាងមុនក្នុងមួយលើកៗ ធ្វើឱ្យការបង្ការជំងឺឆ្កែឆ្កួតកាន់តែងាយជាងមុន ទាំងសម្រាប់គ្រូពេទ្យ ទាំងសម្រាប់អ្នកទទួលថ្នាំបង្ការ។



ថ្នាំបង្ការប្រឆាំងនឹងជំងឺឆ្កែឆ្កួតដែលគេប្រើនាពេលបច្ចុប្បន្ន

## តើប្អូនដឹងទេ?

ដើម្បីធ្វើតេស្តបញ្ជាក់ថា សត្វឆ្កែ ឬសត្វណាមួយមានមេរោគជំងឺឆ្កែឆ្កួត គេត្រូវការយកវត្ថុវិភាគជាខួរក្បាលរបស់សត្វនោះមកពិនិត្យ។ ការពិនិត្យដោយមីក្រូទស្សន៍រកមេរោគជំងឺឆ្កែឆ្កួតត្រូវប្រើមីក្រូទស្សន៍ពិសេសនៅក្នុងបន្ទប់ងងឹត។

## ការស្រាវជ្រាវបច្ចុប្បន្ននៅកម្ពុជា

នៅវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា អ្នកវិទ្យាសាស្ត្រជាតិ និងអន្តរជាតិបន្តស្រាវជ្រាវយ៉ាងសកម្មក្នុងគោលបំណងចូលរួមលុបបំបាត់ជំងឺឆ្កែឆ្កួតទាំងស្រុងនាពេលអនាគត់។ ពួកគេសិក្សាលើរបៀបថ្មីៗក្នុងការប្រើប្រាស់ថ្នាំបង្ការ និងអ៊ីមុយណូគ្លោប៊ុយលីន។

ដោយធ្វើការជាមួយអង្គការសុខភាពអន្តរជាតិនានា ពួកគេក៏ខិតខំរកវិធីសាស្ត្រយ៉ាងណាដែលអនុញ្ញាតឱ្យមនុស្សច្រើនជាងមុនអាចទទួលបានថ្នាំបង្ការជំងឺឆ្កែឆ្កួតមុនក៏ដូចជាក្រោយរងរបួសដោយសត្វខាំ ឬខ្វាច។

ការពិនិត្យវត្ថុវិភាគខួរក្បាលឆ្កែរកវត្តមានមេរោគជំងឺឆ្កែឆ្កួតនៅវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា






វិទ្យាស្ថានប៉ាស្ទ័រកម្ពុជាចូលរួមសកម្មភាពទិវាពិភពលោកប្រឆាំងជំងឺឆ្កែឆ្កួត

## ទិវាពិភពលោកប្រឆាំងជំងឺឆ្កែឆ្កួត

ទិវាពិភពលោកប្រឆាំងជំងឺឆ្កែឆ្កួតត្រូវបានគេប្រារព្ធជារៀងរាល់ឆ្នាំនៅថ្ងៃទី២៨ កញ្ញា ក្នុងគោលបំណងផ្សព្វផ្សាយអំពីការការពារ និងការសម្រេចបាននានា ដើម្បីយកជ័យជម្នះលើជំងឺដ៏កាចសាហាវមួយនេះ។

ថ្ងៃទី២៨ កញ្ញាគឺចំថ្ងៃរំឭកខួបមរណភាពរបស់លោក លូវីស៍ ប៉ាស្ទ័រ អ្នកជំនាញផ្នែកគីមីសាស្ត្រ និងអតិសុខុមប្រាណជនជាតិបារាំង ដែលបានបង្កើតថ្នាំបង្ការទី១ប្រឆាំងនឹងជំងឺឆ្កែឆ្កួត។

បច្ចុប្បន្ននេះ យើងមានថ្នាំបង្ការច្បាស់លាស់ និងមានប្រសិទ្ធភាពសម្រាប់មនុស្ស និងសម្រាប់សត្វ ដើម្បីប្រឆាំងនឹងជំងឺឆ្កែឆ្កួត។

ការផ្សព្វផ្សាយចំណេះដឹងនៅតែជាកត្តាចម្បងនៃជោគជ័យតាមសហគមន៍ក្នុងការរួមចំណែកប្រឆាំងនឹងជំងឺឆ្កែឆ្កួតប្រកបដោយប្រសិទ្ធភាព។

គោលដៅរួមនៃសកលលោកគឺកាត់បន្ថយករណីស្លាប់ដោយជំងឺឆ្កែឆ្កួតបង្កដោយសត្វឆ្កែខាំឱ្យអស់នៅឆ្នាំ២០៣០។

នៅប្រទេសកម្ពុជា ក្នុងថ្ងៃទិវាពិភពលោកប្រឆាំងជំងឺឆ្កែឆ្កួត គេមានធ្វើយុទ្ធនាការផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ កាសែត និងបណ្ដាញសង្គមនានា។ មានសន្និសីទ និងសកម្មភាពសង្គមឯទៀត ដើម្បីឱ្យកុមារក៏ដូចជាមនុស្សពេញវ័យដឹងអំពីការចាក់ថ្នាំបង្ការ និងអំពីគ្រោះថ្នាក់នៃជំងឺឆ្កែឆ្កួត។

### តើប្អូនដឹងទេ?

• ឆ្នាំ១៩៥៣ វិទ្យាស្ថានប៉ាស្ទ័រនៅភ្នំពេញត្រូវបានបង្កើតនៅជ្រោយចង្វារ និងបានចាប់ផ្តើមផ្តល់ថ្នាំបង្ការជំងឺឆ្កែឆ្កួត។ • ឆ្នាំ១៩៧៥ វិទ្យាស្ថានត្រូវបានបិទ។

• ថ្ងៃទី០១ ធ្នូ ១៩៨៦ វិទ្យាស្ថានប៉ាស្ទ័រថ្មីត្រូវបានបើកនៅទួលគោក។

• ឆ្នាំ១៩៩២ ទីតាំងមួយបានផ្តល់ដោយក្រសួងសុខាភិបាលនៅជាប់មន្ទីរពេទ្យកាល់ម៉ែតដោយមានកិច្ចព្រមព្រៀងរវាងរដ្ឋាភិបាលកម្ពុជា និងវិទ្យាស្ថានប៉ាស្ទ័រប៉ារីស។ • ចាប់ពីថ្ងៃទី២៩ មីនា ១៩៩៤ វិទ្យាស្ថានប៉ាស្ទ័រកម្ពុជាបន្តវត្តមានរហូតដល់បច្ចុប្បន្ន ដោយមានទាំងមជ្ឈមណ្ឌលបង្ការជំងឺឆ្កែឆ្កួតផង(សម្ពោធនៅថ្ងៃទី១០ កុម្ភៈ ១៩៩៥)។ ពេលនេះវិទ្យាស្ថានមានបុគ្គលិកជាង ២០០នាក់។ ហេតុអ្វីមិនអាចជារូបប្អូនម្នាក់ដែរ ពេលប្អូនធំឡើង? ប្រទេសកម្ពុជាត្រូវការបុគ្គលិកសុខាភិបាល និងអ្នកស្រាវជ្រាវ ដើម្បីបន្តលើកកម្ពស់ផ្នែកសុខភាព។

## វិទ្យាស្ថានប៉ាស្ទ័រកម្ពុជា

*វិទ្យាស្ថានប៉ាស្ទ័រកម្ពុជាគឺជាវិទ្យាស្ថានមួយដែលមិនរកកម្រៃ បង្កើតឡើងនៅឆ្នាំ១៩៥៣។ វត្ថុបំណងគឺលើកកម្ពស់សុខភាពប្រជាជនកម្ពុជា។ វិទ្យាស្ថានមានសកម្មភាពស្រាវជ្រាវលើជំងឺចម្បងៗ ដូចជាជំងឺឆ្កែឆ្កួត គ្រុនចាញ់ របេង អេដស៍ រលាកថ្លើមជាដើម។ វិទ្យាស្ថានប៉ាស្ទ័រកម្ពុជាមានទីតាំងនៅរាជធានីភ្នំពេញ អគារលេខ៥ មហាវិថីព្រះមុនីវង្ស។ វិទ្យាស្ថានមានបុគ្គលិកជាវេជ្ជបណ្ឌិត ឱសថការី គិលានុប្បដ្ឋាក អ្នកបច្ចេកទេស វិស្វករ អ្នកស្រាវជ្រាវ ដែលបំពេញការងារ ស្រាវជ្រាវវិទ្យាសាស្ត្រ និងវិភាគមន្ទីរពិសោធន៍។*

*វិទ្យាស្ថានមានមជ្ឈមណ្ឌលចាក់ថ្នាំបង្ការចំនួនពីរ។ មជ្ឈមណ្ឌលចាក់ថ្នាំបង្ការជំងឺឆ្កែឆ្កួតទទួលអ្នកមកចាក់ថ្នាំបង្ការក្រោយសត្វខាំ ឬខ្វាច។ ចំណែកមជ្ឈមណ្ឌលចាក់ថ្នាំបង្ការអន្តរជាតិផ្តល់ថ្នាំបង្ការទូទៅដូចជាបង្ការជំងឺតេតាណូស ខាន់ស្លាក់ ក្អកមាន់ របេង រលាកថ្លើម ករញ្ជឹល ផ្តាសាយ មហារីកមាត់ស្បូន គ្រុនលឿងជាដើម។*



រូបអគាររដ្ឋបាលនៃវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា



រូបអគារមជ្ឈមណ្ឌលចាក់ថ្នាំបង្ការជំងឺឆ្កែឆ្កួតនៃវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា

## មជ្ឈមណ្ឌលចាក់ថ្នាំបង្ការជំងឺឆ្កែឆ្កួតនៃវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា

មជ្ឈមណ្ឌលបានត្រូវបង្កើតឡើងនៅឆ្នាំ១៩៩៥ និងមានបេសកកម្មចម្បងគឺផ្តល់ការបង្ការជំងឺឆ្កែឆ្កួត សម្រាប់សាធារណជនក្រោយពេលរងរបួសបង្កដោយសត្វខាំ ឬខ្វាចៗ ការបង្ការនេះចាប់ផ្តើមដោយមិនគិតថ្លៃសេវាទេ រហូតដល់ឆ្នាំ២០១១ ទើបមានការយកថ្លៃក្នុងកម្រិតទាបដោយសារមជ្ឈមណ្ឌលទទួលចំនួនជនរងគ្រោះក្នុងចំនួនកើនឡើងជាលំដាប់គួរឱ្យកត់សម្គាល់ ហើយលែងមានលទ្ធភាពផ្តល់ដោយមិនគិតថ្លៃៗ ចាប់ពីឆ្នាំ២០១០មក ចំនួនអ្នករបួសថ្មីដែលមកទទួលការបង្ការជំងឺឆ្កែឆ្កួតបានកើនដល់ប្រមាណ២ម៉ឺននាក់ក្នុងមួយឆ្នាំៗ

វិធីចាក់ថ្នាំបង្ការនៅសើស្បែកដែលអនុវត្តនៅវិទ្យាស្ថានប៉ាស្ទ័រកម្ពុជាបានអនុញ្ញាតឱ្យអ្នករងរបួសបង្កដោយសត្វទទួលបាននូវការចាក់ថ្នាំបង្ការជំងឺឆ្កែឆ្កួតក្នុងតម្លៃទាបៗ មជ្ឈមណ្ឌលក៏បានសហការជាមួយមន្ទីរពិសោធន៍ផ្នែកវីរុសសាស្ត្រនៃវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា ដើម្បីផ្តល់នូវការធ្វើតេស្តខួរក្បាលសត្វដែលបង្ករបួសដោយឥតគិតថ្លៃៗ លទ្ធផលនៃការវិភាគនឹងជួយតម្រង់ទិសការបង្ការឱ្យកាន់តែបានត្រឹមត្រូវ និងទាន់ពេលវេលា ព្រោះគេចាំបាច់ត្រូវផ្តល់នូវអ៊ីមុយណូគ្លោប៊ុយលីនបន្ថែមលើថ្នាំបង្ការក្នុងករណីលទ្ធផលមន្ទីរពិសោធន៍បញ្ជាក់ថា សត្វនោះមានផ្ទុកមេរោគឆ្កែឆ្កួតៗ

# សាកល្បងរកចម្លើយ

ឥឡូវ ប្អូនបានអានសៀវភៅនេះចប់ហើយ។ ដើម្បីវាស់ស្ទង់កម្រិតយល់ដឹង ប្អូនអាចសាកល្បងឆ្លើយនឹងសំណួរខាងក្រោមនេះ។

**1**

**តើជំងឺឆ្កែឆ្កួតជាអ្វី?**

ក. ជាជំងឺសើស្បែក
ខ. ជាជំងឺប៉ះពាល់ខួរក្បាល
គ. ជាជំងឺប្រព័ន្ធរំលាយអាហារ

**2**

**តើការបង្កជាតនៃជំងឺឆ្កែឆ្កួតប្រព្រឹត្តទៅយ៉ាងដូចម្ដេចនៅក្នុងខ្លួនមនុស្ស?**

ក. មេរោគបង្ករោគនៅត្រង់មុខរបួស
ខ. មេរោគចល័តតាមប្រព័ន្ធប្រសាទទៅបង្ករោគនៅខួរក្បាល
គ. មេរោគចល័តទៅបង្ករោគនៅសួតនាំឱ្យពិបាកដកដង្ហើម

**3**

**តើជំងឺឆ្កែឆ្កួតឆ្លងដោយរបៀបណា?**

ក. ឆ្លងតាមផ្លូវដង្ហើម
ខ. ឆ្លងតាមរបួសដោយមុតវត្ថុមិនស្អាត
គ. ឆ្លងតាមរបួសបង្កដោយសត្វខាំ ឬខ្វាច

**4**

**តើអ្វីខ្លះដែលយើងមិនត្រូវធ្វើ ពេលមានរបួសបង្កដោយសត្វ?**

ក. លាក់មិនឱ្យមនុស្សធំដឹង
ខ. លាងសម្អាតរបួសភ្លាមៗ ដោយទឹកបង្ហូរ ១០ទៅ១៥នាទីជាមួយសាប៊ូ
គ. ប្រាប់ឪពុកម្ដាយឱ្យបានដឹងពីរបួស

**5**

**តើសត្វឆ្កែកើតជំងឺឆ្កែឆ្កួតអាចមានអាការៈដូចម្ដេចខ្លះ?**

ក. ជ្រុះរោមដូចអង្គែស៊ី
ខ. ប្រែជាកាច មិនស្គាល់ម្ចាស់ ហៀរទឹកមាត់ច្រើន
គ. ស្គម និងអត់ស៊ីចំណីច្រើនសប្ដាហ៍

**6** **តើមានថ្នាំព្យាបាលជាស្រឡាច់លាស់ដែរឬទេ សម្រាប់អ្នកកើតជំងឺផ្តាសាយធ្ងន់ធ្ងរ?**

ក. មិនមានឱសថ ឬវិធីព្យាបាល ជាក់លាក់មានប្រសិទ្ធភាពទេ
ខ. ការប្រើថ្នាំផ្សះត្រឹមត្រូវអាចព្យាបាលបាន
គ. គ្រូថ្នាំបុរាណអាចព្យាបាលបាន

**7** **តើជំងឺផ្តាសាយធ្ងន់ធ្ងរបណ្តាលឱ្យស្លាប់ជានិច្ចឬទេ?**

ក. ជាសះស្បើយទៅវិញដោយឯកឯង
ខ. បណ្តាលឱ្យអ្នកជំងឺស្លាប់ជានិច្ច មិនអាចព្យាបាលបាន
គ. ធ្វើឱ្យពិការផ្នែកសតិបញ្ញា ក្រោយពេលជា

**8** **តើចម្លើយមួយណាដែលមិនត្រឹមត្រូវ ទាក់ទងនឹងការចាក់ថ្នាំបង្ការជំងឺផ្តាសាយធ្ងន់ធ្ងរ?**

ក. ចាក់គ្រប់ហើយក៏មិនអាចបង្ការបាន មួយជីវិតដែរ
ខ. ចាក់តែមួយលើកអាចបង្ការបាន មួយជីវិត
គ. បើមានសត្វខាំ ឬខ្លាចជាថ្មី ត្រូវសួរ គ្រូពេទ្យពីការចាក់ថ្នាំបង្ការជំងឺផ្តាសាយជា ថ្មីទៀត ទោះធ្លាប់ចាក់គ្រប់ពីមុនក៏ដោយ

**9** **តើត្រូវលាងសម្អាតរបួសដោយសត្វខាំយ៉ាងដូចម្តេច?**

ក. លាងដោយទឹកបង្ហូរ១០ទៅ១៥នាទី ជាមួយសាប៊ូ និងបន្ទាប់មក ប្រើថ្នាំលាង សម្លាប់មេរោគដូចជាអាល់កុល ឬបេតាឌីន
ខ. លាងសម្អាតរបួស ដោយត្រាំរបួសក្នុង ទឹកសាប៊ូ បន្ទាប់រុំមុខរបួសឱ្យជិត
គ. រុំមុខរបួសភ្លាមៗ មិនលាង រង់ចាំឱ្យពេទ្យលាងឱ្យ

**10** **តើការចាក់ថ្នាំបង្ការជំងឺផ្តាសាយធ្ងន់ធ្ងរអាចធ្វើនៅក្រោយពេលសត្វខាំបានដែរឬទេ?**

ក. មិនអាចធ្វើបានទេ ហួសពេលហើយ
ខ. អាចធ្វើបាន ប៉ុន្តែមិនមែនជាការចាំបាច់ទេ
គ. អាចធ្វើបាន ជាការត្រឹមត្រូវ និងត្រូវ ប្រញាប់ធ្វើកុំរង់ចាំ

**11** **តើវិធីថែទាំរបួសខាងក្រោមណាមួយ ដែលជាវិធីបុរាណ មិនត្រូវអនុវត្ត?**

ក. បំពោកបាយកក លើមុខរបួស
ខ. លាងសម្អាតរបួសដោយទឹកបង្ហូរ និងជាមួយសាប៊ូ
គ. លាងរបួសដោយទឹកអាល់កុល ឬបេតាឌីន

ចម្លើយមាននៅទំព័រទី44

# ពន្យល់ពាក្យ

**ក្រពេញ** ៖ ជាសរីរាង្គទាំងឡាយណាដែលបញ្ចេញរស ឬទឹកនៅក្នុងរាងកាយ ឬចេញមកក្រៅរាងកាយ ដូចជាក្រពេញទឹកមាត់ ក្រពេញទឹកភ្នែកជាដើម។

**ក្រៀវ** ៖ ជាការវះកាត់យកក្រពេញបន្តពូជ(ពងស្វាសរបស់សត្វឈ្មោល ឬអូវែរបស់សត្វញី) ក្នុងគោលបំណងមិនឱ្យសត្វនោះអាចបន្តពូជបាន។

**ណាណូម៉ែត្រ**(nanometre ឬ nm) ៖ ជាខ្នាតរង្វាស់ប្រវែង។ ប្រវែង១ 000 000 ណាណូម៉ែត្របានស្មើនឹង១មីលីម៉ែត្រ (milimetre ឬ mm)

**ថ្នាំបង្ការជំងឺផ្តាសាយបក្សី** ៖ ជាថ្នាំចាក់សម្រាប់ភ្ញោចប្រព័ន្ធការពារខ្លួនឱ្យផលិតកោសិកាក្នុងឈាមប្រឆាំងនឹងវីរុសជំងឺផ្តាសាយបក្សី មិនឱ្យបង្ករោគក្នុងខ្លួនបាន។

**បង្ករោគ** ៖ ជាការបង្កផលប៉ះពាល់ដោយមេរោគនៅកន្លែងណាមួយច្បាស់លាស់នៃរាងកាយ ឬនៅទូទាំងរាងកាយតែម្តង និងស្តែងចេញជារោគសញ្ញានានាទៅតាមប្រភេទមេរោគ។

**ប្រព័ន្ធការពារខ្លួន** ៖ ជាប្រព័ន្ធមានតួនាទីបង្កើតការការពារខ្លួនប្រឆាំងនឹងមេរោគ និងសារធាតុជាក់លាក់នានាដែលអាចឆ្លងចូលមកក្នុងខ្លួន។ ប្រព័ន្ធការពារខ្លួនរួមផ្សំដោយសរីរាង្គមួយចំនួន និងពពួកគ្រាប់ឈាមស។

**ផ្សាំង** ៖ ប្រែក្លាយពីសត្វព្រៃ មិនធ្លាប់រស់នៅជាមួយមនុស្សឱ្យទៅជាសត្វចិញ្ចឹមក្នុងជីវភាពរស់នៅរបស់មនុស្ស

**មន្ទីរបសុព្យាបាល** ៖ មន្ទីរព្យាបាលជំងឺសត្វ។

**មីក្រូទស្សន៍** ៖ ជាឧបករណ៍មានកែវពង្រីករូបសម្រាប់មើលមេរោគតូចល្អិតដែលយើងមិនអាចមើលនឹងភ្នែកឃើញ។

**រោគសញ្ញាជំងឺ** ៖ ជាអាការៈនានាដែលអ្នកជំងឺមាននៅពេលមានជំងឺអ្វីមួយ ដូចជាគ្រុនក្តៅ ក្អក រាក ពិបាកដកដង្ហើម ឈឺក្បាល។ល។

**វីរុស** ៖ ជាប្រភេទមេរោគតូចល្អិតដែលមិនអាចមើលនឹងភ្នែកឃើញទេ។ ដើម្បីអាចមើលឃើញបាន គេប្រើមីក្រូទស្សន៍អេឡិចត្រូនិកដែលមានសមត្ថភាពពង្រីករូបរាប់ពាន់ដង។

**ហានិភ័យ** ៖ ភាពងាយរងគ្រោះចំពោះមុខកត្តាអ្វីមួយ ជំងឺអ្វីមួយ ឬស្ថានភាពអ្វីមួយ។

**អ៊ីមុយណូគ្លោប៊ុយលីន**(Immunoglobuline) ៖ ជាសារធាតុនៃប្រព័ន្ធការពារខ្លួនដែលទាញយកចេញពីឈាមសេះ ឬឈាមមនុស្ស សម្រាប់ប្រើភ្លាមៗទប់ទល់នឹងមេរោគជំងឺផ្តាសាយបក្សី បន្ថែមលើថ្នាំបង្ការ ក្នុងករណីចាំបាច់។ វាមិនមែនជាថ្នាំបង្ការទេ មិនអាចប្រើជំនួសថ្នាំបង្ការបានឡើយ។

**ចម្លើយ** ៖ 1-ខ / 2-ខ / 3-គ / 4-ក / 5-ខ / 6-ក / 7-ខ / 8-ខ / 9-ក / 10-គ / 11-ក

# សិទ្ធិលើរូបភាព

រូបគំនូរ ៖ ទំព័រ៣, ទំព័រ៩, ទំព័រ១០(រូបគោ សំពោចម៉ូហ្វែត ឆ្មា និងប្រចៀវ), ទំព័រ២៦-២៧ និងទំព័រ២៨-២៩ © ស៊ុន ស៊ីណាត
- ទំព័រ៤-៥, ទំព័រ៦-៧ និងទំព័រ២០-២១ © សេង វិសុទ្ធ
- ទំព័រ១០(រូបឆ្កែព្រៃអាហ្វ្រិក និងជ្រូក) © Catherine FICHAUX
- ទំព័រ១៤-១៥ និងទំព័រ១៨-១៩ © ជឿន ប្រុស

រូបថត © Institut Pasteur du Cambodge
លើកលែង ៖
- ទំព័រ១១(វីរុសជំងឺឆ្កែឆ្កួត) © Institut Pasteur de Paris (IPP)
- ទំព័រ១២-១៣ © World Health Organization
- ទំព័រ៣២ © Ella MARCY
- ទំព័រ៣៤b-៣៥(រូបគំនូរលោក ល្វីស ប៉ាស្ទ័រ) និងទំព័រ៣៦ © សារមន្ទីរ IPP
- logos © rabiesalliance.org


# ការថ្លែងអំណរគុណ

យើងខ្ញុំសូមអរគុណជាពិសេសចំពោះ Dr. Hervé BOURHY, M. Eric BOURDONNEAU, Dr. Véronique CHEVALIER, Mme. Anne DELOBEL, លោក សន សុភ័ក្រ, Dr. Arnaud TARANTOLA, វេជ្ជបណ្ឌិត អ៊ិន សុធារី, វេជ្ជបណ្ឌិត តាំង ឈុនណារី, បណ្ឌិត ដួង វាសនា, វេជ្ជបណ្ឌិត អ៊ុង ស៊ីវុធ, Dr. Philippe DUSSART, បណ្ឌិត ស៊ិន សាន, វេជ្ជបណ្ឌិតបសុសាស្ត្រ ហ៊ល ដាវុន, វេជ្ជបណ្ឌិត លី សុវ៉ាន់, ឯកឧត្តមសាស្ត្រាចារ្យ អេង ហួត, ដែលបានផ្តល់ជាអត្ថបទ ជារូបភាព ក៏ដូចជាការគាំទ្រក្នុងការប្រយុទ្ធនឹងជំងឺឆ្កែឆ្កួត។

យើងខ្ញុំក៏សូមអរគុណចំពោះអង្គការសុខភាពពិភពលោក(Organisation Mondiale de la Santé), វិទ្យាស្ថានប៉ាស្ទ័រ ទីក្រុងប៉ារីស(Institut Pasteur de Paris), ក្រសួងអប់រំ យុវជន និងកីឡា, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងសុខាភិបាលដែលបានគាំទ្រការចងក្រងសៀវភៅនេះ។



© គ្រឹះស្ថានបោះពុម្ពផ្សាយSipar
ខែវិច្ឆិកា 2017
ផ្ទះលេខ១ ផ្លូវ334
ប្រអប់សំបុត្រ31
ភ្នំពេញ - កម្ពុជា
ទូរស័ព្ទ : 855 - 23 216 001
edition@sipar-cam.org
www.sipar-books.com



រាល់ការចម្លងទាំងស្រុង ឬ ផ្នែកណាមួយនៃសៀវភៅនេះ ទោះបីតាមរបៀបណាក៏ដោយ បើគ្មានការយល់ព្រមពីអង្គការSipar គឺខុសច្បាប់ និងត្រូវមានទោស។ រក្សាសិទ្ធិចម្លង និងបកប្រែ ចំពោះគ្រប់ប្រទេសទាំងអស់។



បោះពុម្ពនៅប្រទេសកម្ពុជា
ដោយរោងពុម្ព
Sok Heng Printing House

**ឧបត្ថម្ភការបោះពុម្ពដោយ**
**ក្រុមហ៊ុន**

សៀវភៅនៃក្រុមសៀវភៅ **ខ្ញុំចង់ដឹង**
ដែលបានចេញផ្សាយរួចហើយ
















ISBN: 978 99924 340 25 6

9 789924 340256

www.sipar-books.com

Institut Pasteur
du Cambodge